ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល ជាតិ សាសនា ព្រះមហាក្សត្រ

សភាផ្នែក ព្រហ្មទណ្ឌ

សំណុំរឿង ព្រហ្មទណ្ឌ

លេខ : ១០

ចុះថ្ងៃទី១១ ខែកម្ភៈ ឆ្នាំ១៩៩៨

សាលដីកា

លេខ : ១០

ចុះថ្ងៃទី១៧ ខែមិនា ឆ្នាំ១៩៩៩

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ១៧ ខែមិនា ឆ្នាំ១៩៩៩ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅ :

១- ឯកឧត្តម ឌិត មុន្នី ប្រធាន
២- លោក ឈឹម ស៊ីផល ចៅក្រម
៣- លោក សោម សិរីវឌ្ឍ ចៅក្រមរបាយការណ៍
៤- លោក ប្រាក់ គឹមសាន ចៅក្រម
៥- លោក យស់ សូខៀន ចៅក្រម

ក្រឡាបញ្ជី

លោក ទឹម សង្វារិទ្ធិ

តំណាងមហាអយ្យការ

លោក ដួន ស៊ុនទៀង ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ១៧៥ ចុះថ្ងៃទី ២៨ ខែសីហា ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍ និង សំណុំរឿងព្រហ្មទណ្ឌលេខ ១០ ចុះថ្ងៃទី ១១ ខែ កម្ភៈ ឆ្នាំ១៩៩៨ របស់តុលាការកំពូល ។

ពីបទ : ធ្វើមនុស្សឃាតដោយចេតនា ប្រព្រឹត្តិនៅក្រុងភ្នំពេញ កាលពីថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៩៤ បទល្មើសដែលមានចែងនិងផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា៣២ នៃច្បាប់ព្រហ្មទណ្ឌ អន្តរកាលចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ។

-ជនជាប់ចោទឈ្មោះ ស៊ូ ឆុន " ជាម្ចាស់បណ្តឹងសាទុក្ខ " ភេទប្រុស អាយុ៤០ឆ្នាំ ជាតិខ្មែរ កើតនៅឃុំព្រែកល្វង ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល របររកស៊ីនគរបាលចរាចរ មានទីលំនៅសព្វថ្ងៃផ្ទះលេខ២៨០អឺ១ ក្រុម ៣៥ សង្កាត់បឹងរាំង ខណ្ឌដូនពេញ ក្រុងភ្នំពេញ ឪពុកឈ្មោះ ពៅ ស៊ូ " រ " ម្ដាយឈ្មោះ ព្រាប ម៉ែម " ស " ប្រពន្ធឈ្មោះ ពេជ ផល្លា មានកូន ៣នាក់ ។

ក្រៅឃុំ មានមេធាវីលោក ជា តារា ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ គង់ ផារ៉ារិទ្ធិ "ជាចុងបណ្តឹងសាទុក្ខ" ភេទប្រុស ជាតិខ្មែរ របរកស៊ីមន្ត្រីរាជការនៅវិទ្យាស្ថានស្រាវជ្រាវកៅស៊ូ មានទីលំនៅសព្វថ្ងៃផ្ទះលេខ១២២អឺ០ មហាវិថីសីហនុ សង្កាត់បឹងកេងកងទី១ ខណ្ឌចំការមន ក្រុងភ្នំពេញ ។ មេធាវីគ្មាន។

-តាមបណ្តឹងសាទុក្ខលេខ៣៤៥ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៩៧ របស់ឈ្មោះ-ស៊ូ ឆុន ដែលប្តឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ១៧៥ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍លើសេចក្តីសម្រេចទាំងមូល ។

-តាមពាក្យបណ្តឹងចុះថ្ងៃទី២៤-១២-៩៤ របស់ឈ្មោះស៊ូ ឆុន ប្តឹងពីចោរប្លន់ម៉ូតូរបស់ខ្លួនកាលពីថ្ងៃទី២៣-១២-៩៤ វេលាម៉ោង២១ និង ៣០នាទីនៅមុខផ្ទះលេខ១... ម៉ង់បង្កើតឡើងដោយជន៣នាក់បានប្លន់យកម៉ូតូខ្លួន ខ្លួនរត់ចេញពីម៉ូតូបន្តិចក៏ងាកមកវិញ ប៉ុន្តែបែរជាបាញ់ត្រូវជនម្នាក់ផ្សេងដែលជននោះមិនបានយកម៉ូតូខ្លួនឡើយ ។

-តាមកំណត់ហេតុយកចម្លើយចុះថ្ងៃទី០២-០១-៩៥ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ-គង់ ផារិទ្ធិនៅតុលាការក្រុងភ្នំពេញបានឆ្លើយថា៖ នៅថ្ងៃទី២៣-១២-៩៤ វេលាម៉ោងប្រហែលជា២០ ឈ្មោះតាំង គឹមវែម និង វ៉េម បូរ៉ាបានមកលេងផ្ទះខ្លួន លុះដល់ម៉ោងជា២១ ពួកគេក៏ត្រឡប់ទៅផ្ទះរបស់គេវិញ បានប្រហែលកន្លះម៉ោងក្រោយមក ខ្លួនបានទទួលដំណឹងថា ឈ្មោះ វ៉េម-បូរ៉ា ត្រូវរបួសដោយគេបាញ់សំរាកនៅមន្ទីរពេទ្យកាលម៉ែត ។ខ្លួនសុំទាមទារជម្ងឺចិត្តពីជនល្មើសចំនួន ២ ម៉ឺនដុល្លា ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការអម តុលាការក្រុងភ្នំពេញថា៖

-មានមូលដ្ឋានចោទប្រកាន់លើឈ្មោះស៊ូ ឆុន ពីបទធ្វើមនុស្សឃាតដោយចេតនាតាមមាត្រា៣២ច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-គ្មានមូលដ្ឋានចោទប្រកាន់លើឈ្មោះតាក់ លាងហួរ និងតាំងគឹម-វែមពីបទបង្ករបួសស្នាមលើអ្នកដទៃ គប្បីលើកលែងចោទប្រកាន់ ។

-ជូនរឿងទៅតុលាការវិនិច្ឆ័យតាមច្បាប់ ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ២២ "គ" ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ១៩៩៥ របស់តុលាការក្រុងភ្នំពេញដែលបានសំរេច ៖

១- អោយឈ្មោះស៊ូ ឆុន រួចខ្លួនពីការចោទប្រកាន់ពីបទធ្វើមនុស្សឃាតដោយចេតនាប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី២៣-១២-៩៤ ។

២- អោយដោះលែងជាបន្ទាន់ឈ្មោះស៊ូ ឆុនប្រសិនបើឈ្មោះនេះមិនត្រូវបានឃុំខ្លួនពីបទល្មើសផ្សេងទៀតទេ ។

៣- វត្ថុតាងដកហូតមាន ៖

-អាវុធម៉ាកកា៥៩ លេខ៨៤០៨បង់មួយគ្មានគ្រាប់ ។

-លិខិតអនុញ្ញាតអោយប្រើប្រាស់អាវុធលេខ០១០១៣៧មួយ ។

-ម៉ូតូឌុបប្រជុំងអាគុយស្លាកពណ៌ទឹកប៊ិចលេខតួលេខ៥០.៩១៨៨១៥៥ លេខម៉ាស៊ីន លេខ៥០អឹ.៩២៨៨១៨៨ មួយគ្រឿងត្រូវប្រគល់អោយស៊ូ នុនវិញ ។

-ដំបងមួលមួយពណ៌ឈាមជ្រូកប្រវែង០,៥ម ត្រូវរឹបអូសនិងបំផ្លាញចោល។

៤-សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខគូភាគីសំរេចបើកផ្លូវឧទ្ធរណ៍រយៈពេល២ខែ គិតចាប់ពីថ្ងៃនេះតទៅ ។

-បាន ឃើញពាក្យបណ្តឹងឧទ្ធរណ៍លេខ១៦ "គ" ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ១៩៩៥របស់លោក គង់-ដារ៉ា រិទ្ធិ ដែលប្តឹងតវ៉ាពីសាលក្រមព្រហ្មទណ្ឌលេខ២២ "គ" ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ១៩៩៥របស់តុលាការក្រុងភ្នំពេញ លើសេចក្តីសំរេចទាំងមូល ។

-បាន ឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមសាលាឧទ្ធរណ៍ថា :

១-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី៣-៥-៩៥របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ -គង់ ដារ៉ា រិទ្ធិទុកជាត្រឹមត្រូវតាមទំរង់ និង នីតិច្បាប់ ។

២-បដិសេធសាលក្រមព្រហ្មទណ្ឌលេខ២២ "គ" ចុះថ្ងៃទី ២៨-៤-៩៥ របស់តុលាការក្រុងភ្នំពេញ ចោលជាអាសារបង់ ។

៣-ចោទប្រកាន់ឈ្មោះស៊ូ នុន ពីបទៈ ធ្វើមនុស្សឃាតដោយចេតនា ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី២៣-១២-៩៤ តាមបញ្ញត្តិមាត្រា៣២ច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-បាន ឃើញសាលដីកាកំបាំងមុខព្រហ្មទណ្ឌលេខ១៥៦ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៩៦របស់សាលាឧទ្ធរណ៍ដែលបានសំរេច :

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី៣-៥-៩៥របស់ដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះគង់ ដារ៉ា រិទ្ធិទុកជាត្រឹមត្រូវតាមទំរង់ និង នីតិច្បាប់ ។

២-បដិសេធសាលក្រមព្រហ្មទណ្ឌលេខ២២ "គ" ចុះថ្ងៃទី២៨-៤-៩៥របស់តុលាការក្រុងភ្នំពេញ ចោលជាអាសារបង់ ។

៣-ផ្តន្ទាទោសឈ្មោះស៊ូ នុនដាក់ពន្ធនាគារកំណត់ ៨ឆ្នាំគិតចាប់ពីថ្ងៃចាប់ខ្លួនលើកទី២ ដោយដករយៈពេលឃុំខ្លួនលើកទី១ចំនួន៥៦ថ្ងៃចេញពីបទៈ ធ្វើមនុស្សឃាតដោយចេតនាមានអាវុធតាមបញ្ញត្តិមាត្រា៣២ ,៦៨ ច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៤-បង្គាប់អោយឈ្មោះស៊ូ នុន សងប្រាក់សំណងរដ្ឋប្បវេណីចំនួន៥០០០ដុល្លា ទៅដើមបណ្តឹងរដ្ឋប្បវេណីសំណូមពរលើសពីនេះបដិសេធចោល ។ ក្នុងករណីទណ្ឌិតគ្មានប្រាក់សងធនទណ្ឌទេ បង្គាប់អោយដាក់គុកបង្ខំដល់រូបកាយតាមមាត្រា ៣ ច្បាប់ស្តីពីការដាក់គុកបង្ខំដល់រូបកាយក្នុងរឿងព្រហ្មទណ្ឌ។

៥-សំភារៈដកហូតមាន :

-អាវុធម៉ាកកា៥៩ លេខ៨៤០៨បង់មួយគ្មានគ្រាប់ត្រូវរឹបអូសនិងប្រគល់អោយ

អង្គភាពនគរបាលចរាចរណ៍ផ្លូវគោក ។

-ម៉ូតូម៉ាកឆាលីពណ៌ខៀវ លេខម៉ាស៊ីនហុងដា សេ៥០អឺ:២៧៥២៣៦៣ លេខតួ-ហុងដាអឺ៥០:២៧២៦០០ ត្រូវប្រគល់អោយដើមបណ្តឹងរដ្ឋប្បវេណីវិញ ។

-ម៉ូតូម៉ាកគុបប្រដុងអាគុយស្កូតពណ៌ទឹកប៊ិច លេខតួ សេ៥០៩៦៨៨១៥៥ លេខម៉ាស៊ីន សេ៥០អឺ:៩៦៨៨១១៨មួយគ្រឿងត្រូវឃាត់ទុកដើម្បីធានាសំណងរដ្ឋប្បវេណី ។

-ដំបងមូលពណ៌ឈាមជ្រូកប្រវែង៦០ , ៥ម ត្រូវរឹបអូសនិងបំផ្លាញចោល ។

៦_សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខមេធាវីជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី និង មេធាវីការពារអោយដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់-ចោទ សំរេចបើកផ្លូវប្តឹងទាស់ សាទុក្ខក្នុងកំណត់ច្បាប់ ។

-បានឃើញបណ្តឹងទាស់លេខ៣៧ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩៦ របស់ឈ្មោះស៊ូ ឆុន ដែលប្តឹងតវ៉ាពីសាលដីកាកំបាំងមុខព្រហ្មទណ្ឌលេខ១៥៦ ចុះថ្ងៃ២៩ ខែមិថុនា ឆ្នាំ១៩៩៦របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ១៧៥ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍ដែលបានសំរេច :

១_ទទួលពាក្យបណ្តឹងទាស់ចុះថ្ងៃទី២៥-១០-៩៦របស់ជនជាប់ចោទឈ្មោះ -ស៊ូ ឆុនទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែលើកចោលដោយទាស់ខុសនឹងគតិច្បាប់ ។

២_តម្កល់សាលដីកាកំបាំងមុខលេខ១៥៦ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ១៩៩៦របស់សាលាឧទ្ធរណ៍ទុកជាបានការ ប៉ុន្តែលើកលែងចំណុចទី៣ដែលត្រូវកែប្រែជា :

-ផ្តន្ទាទោសឈ្មោះស៊ូ ឆុនដាក់ពន្ធនាគារកំណត់ ៣ឆ្នាំចាប់គិតពីថ្ងៃចាប់ខ្លួនបានលើកទី២ ដោយដករយៈពេលឃុំខ្លួនលើកទី១ចំនួន ៥៦ថ្ងៃចេញ ពីបទធ្វើមនុស្សឃាតដោយចេតនាមានអាវុធប្រព្រឹត្តិនៅក្រុងភ្នំពេញកាលពីថ្ងៃទី២៣-១២-៩៤ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង អោយផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣២ , ៦៨ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៣_សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខមេធាវីដើមបណ្តឹងរដ្ឋប្បវេណី និង មេធាវីជនជាប់ចោទ ប៉ុន្តែចាត់ទុកជាចំពោះមុខជនជាប់ចោទនិងដើមបណ្តឹងរដ្ឋប្បវេណី សំរេចបើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

-បានឃើញបណ្តឹងសាទុក្ខលេខ៣៤៥ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៩៧របស់ឈ្មោះ-ស៊ូ ឆុន ដែលប្តឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ១៧៥ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ១៩៩៧របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

-បានឃើញសារណាចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ១៩៩៨របស់ឈ្មោះស៊ូ ឆុន ជាម្ចាស់បណ្តឹងសាទុក្ខ ដែលធ្វើឡើងក្នុងកំណត់ច្បាប់ ។

-បានឃើញសារណាឆ្លើយតបចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៨៧ របស់លោកគង់ ផារ៉ាឫទ្ធិ "ជាចុងបណ្តឹងសាទុក្ខ" ដែលធ្វើឡើងក្នុងកំណត់ច្បាប់ ។

-បានស្តាប់អំណានសាវតាជាតិរបស់ជនជាប់ចោទឈ្មោះ ស៊ូ ឆុន "ជាម្ចាស់បណ្តឹងសាទុក្ខ" នៅពេលជំនុំជំរះ ។

-បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អម តុលាការកំពូល ថា ៖ សាលដីកាលេខ១៣៥ ចុះថ្ងៃទី២៨-៨-៨៧ របស់សាលាឧទ្ធរណ៍ដែលសំរេចសេចក្តីមកនេះគឺត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ហើយ ម្យ៉ាងទៀតដើមបណ្តឹងរដ្ឋប្បវេណីយល់ព្រមចំពោះទណ្ឌកម្ម ដែលសាលាឧទ្ធរណ៍បានបន្ថយពីដាក់គុក៨ឆ្នាំមកជា៦ឆ្នាំវិញផងដែរ ។ ហេតុនេះសូមក្រុមប្រឹក្សាជំនុំជំរះពិនិត្យ និង សំរេច ។

-បានស្តាប់អំណានសារណារបស់ឈ្មោះ ស៊ូ ឆុន "ជាម្ចាស់បណ្តឹងសាទុក្ខ" នៅពេលជំនុំជំរះ ។

-បានស្តាប់ចម្លើយអះអាងរបស់លោកគង់ ផារ៉ាឫទ្ធិ "ជាចុងបណ្តឹងសាទុក្ខ" នៅពេលជំនុំជំរះថា សារណារបស់ជនជាប់ចោទគ្រាន់ជាពាក្យដោះសារ ហើយក៏ពុំមែនបានញាំទៅលើជនរងគ្រោះជាការការពារស្របច្បាប់ដែរ ។ ម្យ៉ាងទៀតជនរងគ្រោះគ្មានអាវុធអ្វីម្បីតបតទៅជនជាប់ចោទឡើយ ។ ដូច្នេះអំពើជនជាប់ចោទពិតជាមានចេតនាសំលាប់ជនរងគ្រោះប្រាកដមែន ។សូមតុលាការសំរេចតាមច្បាប់និងប្តឹងទាមទារជម្ងឺចិត្តចំនួន ៥០០០ដុល្លា ។

-បានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់លោកជា តារា ជាមេធាវីការពារអោយជនជាប់ចោទឈ្មោះ ស៊ូ ឆុន នៅពេលជំនុំជំរះថា ៖ កូនក្តីរបស់ខ្ញុំពិតជាការពារស្របច្បាប់មែន ប៉ុន្តែគ្រាន់តែច្បាប់ពុំបានចែង ។ ដូច្នេះសូមតុលាការកំពូលបង្កើតជាយុត្តិសាស្ត្រនិងលើកលែងចោទប្រកាន់កូនក្តីខ្ញុំទ ដោយអនុគ្រោះ ។

-បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមនាពេលសវនាការរបស់តំណាងមហាអយ្យការ អម តុលាការកំពូលថា ៖ អំពើជនជាប់ចោទគឺមានចេតនាសំលាប់មនុស្ស ពេញទំហឹងហួសព្រំដែនការពារខ្លួនស្របច្បាប់ ព្រោះជនរងគ្រោះពុំមានអ្វីតទល់ទេ ។ សូមតុលាការសំរេចតាមច្បាប់ ។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សារណារបស់ជនជាប់ចោទ ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និង សេចក្តីសន្និដ្ឋានការពាររបស់មេធាវីជនជាប់ចោទ ។

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ១៣៤៥ ចុះថ្ងៃទី១៥-៨-៨៧ របស់ឈ្មោះ ស៊ូ ឆុន ប្តឹងពីសាលដីកាព្រហ្មទណ្ឌលេខ១៣៥ ចុះថ្ងៃទី២៨-៨-៨៧ របស់សាលាឧទ្ធរណ៍លើសេចក្តីសំរេចទាំងមូលធ្វើឡើងក្នុងកំណត់ច្បាប់

តុលាការកំពូលអាចលើកយករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤នៃច្បាប់ស្តីពីការចាត់តាំងនិងសកម្មភាព
របស់សាលាជំរះក្តី ។

- យល់ឃើញថា មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ឈ្មោះស៊ួ នុន ពិតជាបានប្រព្រឹត្តិអំពើ
មនុស្សឃាតដោយចេតនា កាលពីថ្ងៃទី២៣ - ១២ - ៩៤វេលាម៉ោង២២ និង ៤០នាទីតាមមហាវិថីព្រះមុនីវង្ស
ម្តុំធនាគារទីលានម៉ៃប្រាកដរមែន ។ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្តន្ទាទោសតាមមាត្រា៣២នៃច្បាប់
ព្រហ្មទណ្ឌអន្តរកាល ។

- យល់ឃើញថា ការលើកឡើងរបស់ជនជាប់ចោទក្នុងសារណាការពាររបស់ខ្លួនថា ការបាញ់
សំលាប់ជនរងគ្រោះ គឺជាការការពារខ្លួនស្របច្បាប់នោះ នោះជាការភន្ល័ច្រឡំពីព្រោះជនរងគ្រោះ
មានតែដំបងខ្លីតូចមួយ រួចជនជាប់ចោទប្រើកាំភ្លើងបាញ់ទៅលើជនរងគ្រោះចំនួន ៣គ្រាប់ ។

- យល់ឃើញថា ក្នុងសារណាថ្លែងតបចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ១៩៩៨ដើមបណ្តឹងរដ្ឋប្បវេណី
បានលើកឡើងឯកភាពចំពោះទោសគុកដែលសាលាឧទ្ធរណ៍ផ្តន្ទាទោសជនជាប់ចោទហើយ ។

- យល់ឃើញថា ជនជាប់ចោទបានធ្វើសារណាជូនមកតុលាការកំពូលនិងបានទទួលដីកាកោះហើយ
ប៉ុន្តែពុំបានចូលរួមនាសវនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំជំរះរឿងនេះកំបាំងមុខជនជាប់ចោទប៉ុន្តែ
ចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ១៣៥ ចុះថ្ងៃទី២៩ - ៨ - ៩៧របស់សាលាឧទ្ធរណ៍ដែល
សំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវទាំងទំរង់ ទាំងអង្គច្បាប់ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តីចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទ
ប៉ុន្តែចាត់ទុកជាចំពោះមុខ :

១ - ទទួលបណ្តឹងសាទុក្ខលេខ៣៤៥ ចុះថ្ងៃទី១៥ ៩ ៩៧របស់ឈ្មោះស៊ួ នុន ទុកជាត្រឹមត្រូវតាម
ទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងអង្គច្បាប់ ។

២ - តម្កល់សាលដីកាព្រហ្មទណ្ឌលេខ១៣៥ ចុះថ្ងៃទី២៩ - ៨ - ៩៧ របស់សាលាឧទ្ធរណ៍ទុកជាបានការ
ពេញទាំងមូល ។

៣ - សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី១៧ ខែមិនា ឆ្នាំ១៩៩៩ ។